# ធម្មកថា

## របស់ព្រះតេជព្រះគុណបណ្ឌិតហុក-សាវណ្ណ
## អំពីពុទ្ធភាសិតមួយបទថា ធម្មរសឈ្នះអស់រសទាំងពួង

**web site: hoksavann.org**

ថ្ងៃទី២០ សីហា ២០០៥

ពាក្យថា <ធម្មរសឈ្នះអស់រសទាំងពួង> នេះ ចេញមកពីពុទ្ធភាសិតជាបាលីថា សព្វរសំ ធម្មរសោ ជិនាតិ ។ ពាក្យនេះពោលបញ្ជាក់អំពីរសទាំងអស់ក្នុងលោក ប្រៀបធៀបនឹងរសព្រះធម៌ ថារសព្រះធម៌ប្រសើរដាច់អស់រសទាំងពួង ។ រសក្នុងលោក ដូចជារសដែលកើតអំពីការស្រឡាញ់ចូលចិត្តក្នុងកាមគុណ៥គឺ រូប ស់ម្លេង ក្លិន រស និង សម្ផស្ស ដែលមនុស្សផងតែងស្រឡាញ់ចូលចិត្តនោះ គឺបានសប្បាយបានសុខស្រួលតែក្នុងមួយខណ:មួយពេលប៉ុណ្ណោះ ក៏ត្រូវបាត់ទៅវិញ ។ ក្នុងបដិច្ចសមុប្បាទធម៌និយាយថា វេទនាជាសុខជាទុក្ខ កើតមកពីផស្ស: គឺការប៉ះទង្គិចរវាងអាយតន:ខាងក្នុង គឺភ្នែក ត្រចៀក ច្រមុះ អណ្តាត កាយ និង មនោ ជាមួយនិងរូប សម្លេង ក្លិន រស សម្ផស្ស និង ធម្ម: (វត្ថុដែលចិត្តគោង) ធម្មជាតិទាំងនេះ សុទ្ធតែជាសភាវ:ពុំទៀង ដូច្នេះវេទនាជាសុខជាទុក្ខ ក៏ស្ថិតនៅក្នុងសភាពពុំទៀង តែងប្រែប្រួលដូចគ្នា ។ ភ្នែកប៉ះនឹងរូប ត្រចៀកប៉ះនឹងសម្លេង កើតការស្រឡាញ់ចូលចិត្ត ថារូបស្អាតរូបល្អ សម្លេងពិរោះ ក៏កើតចិត្តសប្បាយជាតួសោមនស្សវេទនាផ្លូវចិត្ត បានតែមួយខណ:មួយពេលក៏បាត់ទៅវិញ ។ ច្រមុះប៉ះនិងក្លិន មានចិត្តរីករាយនិងក្លិនក្រអូប ពុំយូរប៉ុន្មានក៏បាត់ទៅ ។ អណ្តាតប៉ះនឹងរសជាតិអាហារបានឆ្ងាញ់តែត្រឹមអណ្តាត លុះលេបផុតពីបំពង់កទៅ ការឆ្ងាញ់ពិសារនោះក៏បាត់ទៅ ។ ចិត្តនឹញគិតប៉ះអារម្មណ៍ជាទីសប្បាយផ្លូវចិត្ត ពុំយូរប៉ុន្មានដូរផ្លាស់ជាទោមនស្សវិញ ។ នេះជារសកើតមកពីការត្រេកអរក្នុងផ្លូវកាមគុណក្នុងកាមភព ។ ចំណែកសុខក្នុងរូបភាពនិងអរូបភាព ក៏ស្ថិតនៅក្នុងសភាពប្រែប្រួលដូរផ្លាស់ទាំងអស់ ព្រោះថាភពទាំងបីនេះស្ថិតនៅក្នុងសភាពពុំទៀងជាទុក្ខ (បរិណាមទុក្ខ គឺទុក្ខកើតអំពីការប្រែប្រួល) និងជាអនត្តា ។

ចំណែកធម្មរស ប្រែថារសនៃព្រះធម៌ មានតម្លៃកាត់ថ្លៃពុំបាន ។ ព្រះបរិយត្តិធម៌ បានដល់ព្រះត្រៃបិដកជាធម៌ គឺព្រះពុទ្ធសំដែងល្អហើយ សំដែងត្រឹមត្រូវហើយ ជាមាគ៌ាដឹកនាំសត្វឲ្យចេញចាកទុក្ខ ។ ព្រះធម៌របស់ព្រះពុទ្ធបានបង្ហាញនូវមាគ៌ាជីវិតពិតប្រាកដ រមែងញ៉ាំងអ្នកប្រតិបត្តិតាមឲ្យបានម៉ត់ចត់ និងបានទទួលនូវរសមួយនៅទីបំផុត ហៅថាបីមុត្តិរស ឬនិព្វានរសជាទីបំផុត ទុក្ខលែងវិលកើតវិលស្លាប់ក្នុងសង្សារវដ្ត ។ រសជាតិនៃព្រះធម៌នៅតែកើតមានគ្រប់កាលសម័យនិងគ្រប់ទីកន្លែង ឲ្យតែគេប្រតិបត្តិនូវធម៌ដ៏សមគួរដល់ធម៌ ។ សង្គមមនុស្ស បើមនុស្សមានមេត្តា ករុណា ពុំបៀតបៀនគ្នា នឹងបានទទួលនូវរសមួយ គឺសង្គមរស គឺធ្វើឲ្យសង្គមមានសុខសន្តិភាព ។ ការក្រេបជញ្ជក់យករសជាតិព្រះធម៌ ឈ្មោះថាក្រេបយកអមតធម៌ ប្រែថាធម៌ពុំស្លាប់បានដល់ព្រះនិព្វាន ដែលព្រះអរហន្តទាំងឡាយមានព្រះពុទ្ធជាដើមបានសំរេចហើយ ។

បើប្រៀបធៀបសេចក្តីសុខក្នុងកាមគុណ៥ វាបានសុខខ្លះ ប៉ុន្តែសេចក្តីសុខនោះ ពុំយូរប៉ុន្មានវាត្រូវប្រែប្រួលទៅជាក្តៅក្រហាយចិត្ត ប្រកបដោយការសោកសៅវិញ រហូតប្រព្រឹត្តធ្វើអំពើអកុសលថែមទៀត ។ ចំណែករសព្រះធម៌ រមែងញ៉ាំងឲ្យមនុស្សសត្វដែលប្រតិបត្តិតាម ឲ្យដល់នូវភាពស្ងប់ ពុំក្តៅក្រហាយដោយភ្លើងកិលេស គឺលោភ: ទោស: មោហ: រមែងបានសុខក្សេមក្សាន្តក្នុងលោកនេះ និងលោកខាងមុខ និងសុខជាន់ខ្ពស់ គឺព្រះនិព្វាន ។ បើធម្មរសកើតមានក្នុងលោក នឹងធ្វើឲ្យសង្គមមនុស្សក្នុងសកលលោកបានសុខសន្តិភាព ឯការច្បាំងគ្នាប្រកបដោយអំពើហឹង្សារមែងពុំកើតមានឡើយ ។ ដូច្នេះធម្មរសពិតជាឈ្នះអស់រសទាំងពួង ។៚